ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មិថុនា ២០០៥ / June 2005

កញ្ញា អ៊ុច ចំន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុត្ថា / **Mr. Hing Vutha**

លោក ភីម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី១ ២00៥ គំរោងវិនិយោគឯកជនបានអនុម័តសំរាប់វិស័យសេវា មានជាអាទិ៍ សណ្ឋាគារ ទេសចរណ៍ និងសេវាកម្មឯទៀត មានតំលៃ ៥៣,៣លានដុល្លារ ក្នុងនេះ ខាងសណ្ឋាគារមាន ៤២,៤លានដុល្លារ, ខាងទេសចរណ៍ ៤លានដុល្លារ (កន្លែងវាយកូលគោល និងក្លឹបកីឡា) និង សេវាដទៃទៀត ៧លានដុល្លារ។ កាលពីមួយឆ្នាំមុន វិនិយោគក្នុងវិស័យសេវាមានត្រឹមតែ ៩,៥លានដុល្លារប៉ុណ្ណោះ ។

Private investment approvals in the service sector, which includes hotels, tourism and other services, amounted to $53.3 million in the first quarter of 2005. Of this, $42.4 million and $4 million were invested in hotels and tourism (e.g. golf course and sport club complex), respectively. The remaining $7 million was for other services. A year ago, investment in the service sector registered only $9.5 million.

**Private Investment in Services Sector Approved by CDC** (US$ million)




*Note: Data include expansion project approvals.*
Source: Council for the Development of Cambodia

តាំងពីត្រីមាសទី២ ២00៤ មក ចំនួនទេសចរបរទេសមកដល់កម្ពុជាតាមយន្តហោះកើនឡើងជានិច្ចរហូតដល់ ២៣១.៧៣៦នាក់ នៅត្រីមាសទី១ ២00៥ ។ ផ្ទុយទៅវិញ ភ្ញៀវចូលកម្ពុជាតាមផ្លូវគោកនិងទឹក ថយចុះដល់ ១៤៨.៨៦៣នាក់ នៅត្រីមាសទី១ ក្រោយពេលកើនឡើងបានពីរត្រីមាសជាប់គ្នា។ ធៀបនឹងត្រីមាសទី១ ឆ្នាំមុន ភ្ញៀវចូលតាមផ្លូវអាកាស និងផ្លូវគោក/ទឹក ស្ទុះឡើងយ៉ាងខ្លាំង ដល់ ៤៧% និង ៥៤% រៀងគ្នា ។

The number of foreign visitor arrivals to Cambodia by air has continued to increase since the second quarter of 2004, reaching 231,736 persons in the first quarter of 2005. On the other hand, visitors entering Cambodia by land and boat declined to 148,863 persons in the first quarter, after increasing for two consecutive quarters. Compared to the first quarter of last year, arrivals by air and by land and boat jumped sharply, by 47 percent and 54 percent respectively.

**Foreign Visitor Arrivals to Cambodia by Air, Land and Boat** (thousand persons)




*Note: Latest data available are for March 2005.*
Source: Ministry of Tourism

នៅត្រីមាសទី១ ២00៥ គំរោងសាងសង់អនុម័តដោយសាលាក្រុងភ្នំពេញមានតំលៃប្រហែល ១0៦លានដុល្លារ ធៀបនឹង ៦៤លានដុល្លារនៅត្រីមាសមុន ។ ក្នុងនេះ គំរោងសំណង់ផ្ទះល្វែងសឹងគ្មានប្រែប្រួល (កើនពី ៤៦,៣ ដល់ ៤៨,៦លានដុល្លារ), ឯគំរោងជាភូមិគ្រឹះ/ផ្ទះ និងសំណង់ផ្សេងទៀតកើនយ៉ាងខ្លាំង (ពី ៥,៥ ដល់ ១៤,៣លានដុល្លារ និង ពី ១២,៤ ដល់ ៤៣,១លានដុល្លាររៀងគ្នា) ។

Construction projects approved by the municipality of Phnom Penh were valued at around $106 million in the first quarter of 2005, compared to $64 million in the preceding quarter. During this period, the value of apartment construction projects remained almost unchanged (from $46.3 million to $48.6 million), while villa and house and other construction projects rose sharply (from $5.5 million to $14.3 million and from $12.4 million to $43.1 million). Compared to the first quarter one year earlier, the total value of construction project approvals in Phnom Penh increased by 46 percent.

**Value of Construction Project Approvals in Phnom Penh**
(US$ million)




Source: Department of Cadastre and Geography, The Municipality of Phnom Penh.

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

ពីខែមេសា ដល់ ឧសភា ២០០៥ នៅភ្នំពេញ ថ្លៃ សាំង ម៉ាស៊ូត និង អង្ករលេខ២ នៅនឹងត្រឹម ៣.២៣៥រៀល/លីត្រ, ២.៤៧៥រៀល/លីត្រ និង ១.០៥០រៀល/គ.ក រៀងគ្នា ដែលកាលពីខែឧសភា ២០០៤ វាមានក៏រិតត្រឹម ២.៨០០រៀល/លីត្រ, ២.០០០រៀល/លីត្រ និង ៩៥៥រៀល/គ.ក រៀងគ្នា ។

The average prices of gasoline, diesel oil and second quality rice in Phnom Penh remained stable at 3,235 riels/litre, 2,475 riels/litre and 1,050 riels/kg, respectively, from April to May 2005. The same prices were only 2,800 riels/litre, 2,000 riels/litre and 955 riels/kg in May 2004.

## Price of Gasoline, Diesel Oil and Second Quality Rice in Phnom Penh




Sources: CDRI and National Institute of Statistics

ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបន្តកើនឡើង (១,៣%) ពីខែមីនា ដល់ មេសា ២០០៥ ក្នុងនេះ ថ្លៃម្ហូបអាហារ និងដឹកជញ្ជូន កើន ២,៨% និង ១% រៀងគ្នា ។ ពីខែមេសា២០០៤ ដល់ មេសា២០០៥ ថ្លៃទំនិញប្រើប្រាស់សរុបនៅភ្នំពេញកើនប្រហែល ៦% ធៀបនឹង ១,៦% ក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០០៣-២០០៤ ។ រឿងនេះឆ្លុះបញ្ចាំងពីកំណើនធំជាងមុនក្នុងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ ដែលកើនពី ២,៥% ដល់ ៨,៤% និង ពី ៥% ដល់ ១២,២% រៀងគ្នា ។

Consumer prices in Phnom Penh continued to rise (1.3 percent) from March to April 2005. The price of food and cost of transportation rose by 2.8 percent and 1 percent, respectively, during this period. Overall consumer prices in Phnom Penh increased by about 6 percent over April 2004-2005, compared to a 1.6 percent increase over April 2003-2004. This reflected the greater increases in food and fuel prices, which rose by 8.4 percent from 2.5 percent and by 12.2 percent from 5 percent, respectively.

## Consumer Price Index

(July–December 2000=100)




*Note: Latest data available are for April 2005.*
Source: National Institute of Statistics

នៅខែកុម្ភៈ ២០០៥ ប្រាក់ចំនូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញឡើងដល់ ១៤.៤០០រៀល រឺកើន ៨%ខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ។ ប៉ុន្តែប្រាក់ចំនូលប្រចាំថ្ងៃពិតរបស់កម្មកររោងចក្រកាត់ដេរ ថយចុះអស់ ១,២% ដល់ ៩.២០០រៀល យោងតាមអង្កេតរបស់ វបសអ លើពលករងាយរងគ្រោះនៅភ្នំពេញ ។

The real daily earnings of skilled construction workers rose to 14,400 riels in February 2005, 8 percent higher than in the same month last year. However, the real daily earnings of garment workers declined by 1.2 percent to 9,200 riels, based on CDRI's survey of vulnerable workers in Phnom Penh.

## Real Average Daily Earnings of Garment and Skilled Construction Workers in Phnom Penh




*Note: November 2000 =100.*
Source: CDRI

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ

# Exchange Rate and Monetary Developments

ពីខែមេសា ដល់ ឧសភា ប្រាក់រៀលធ្លាក់ថ្លៃយ៉ាងខ្លាំងទល់នឹងដុល្លារ ដោយប្តូរបាន ៤.០៨០រៀល/ដុល្លារនៅខែឧសភា ធៀបនឹង ៤.០៣០រៀល/ដុល្លារនៅខែមេសា ។ បើធៀបនឹងខែឧសភាឆ្នាំមុន ប្រាក់រៀលក៏ចុះថ្លៃអស់ ១,៥% ដែរ ពីកំរិត ៤.០២០រៀល/ដុល្លារ ។

The riel fell sharply against the US dollar between April and May, trading at 4,080 riels/dollar in May, from 4,030 riels/dollar in April. The riel also depreciated against the dollar as compared to May a year earlier (by 1.5 percent from 4,020 riels/dollar).

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

នៅខែឧសភា ២០០៥ ប្រាក់រៀលចុះថ្លៃទល់នឹងប្រាក់បាតថៃ ក្រោយពីបានឡើងថ្លៃនៅខែមុន ប៉ុន្តែបានបន្តចុះថ្លៃទល់នឹងប្រាក់ដុងវៀតណាម ។ ប្រាក់រៀលប្តូរបាន ១០៣,៣៤រៀល/បាត និង ២៥,៤៣រៀល/១០០ដុង នៅខែឧសភា ធៀបនឹង ១០២,៣រៀល/បាត និង ២៥,៣រៀល/១០០ដុង នៅខែមុន ។ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ប្រាក់រៀលចុះថ្លៃអស់ប្រហែល ៣% ទល់នឹងប្រាក់បាត និងប្រាក់ដុង ទាំងពីរនេះ ។

The riel depreciated against the Thai baht in May 2005, after appreciating in the preceding month, while the riel continued to fall against the Vietnamese dong. The riel traded at 103.34 riels/baht and 25.43 riels/100 dong in May, from 102.3 riels/baht and 25.3 riels/100 dong in the preceding month. Compared to the same month last year, the riel depreciated by around 3 percent against both the baht and the dong.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI and the *Economist*

រូបិយវត្ថុទូទៅរបស់ប្រព័ន្ធធនាគារ បន្តកើនបាន ១,៤% នៅខែមីនា គឺលឿនជាងកាលពីខែមុនដែលវាបានកើនឡើងតែ ០,៥% ។ ក្នុងកំណើននេះ សមាសភាគជារៀលកើន ២,១% ដល់ ១.៣១១,៣ពាន់លានរៀល រីឯតំលៃប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ១,២% ដល់ ៣.១៨៩,៣ពាន់លានរៀល (ស្មើនឹង ៧៩១,២លានដុល្លារ) ។

Liquidity of the banking system continued to rise, at a rate of 1.4 percent in March, faster than in the preceding month, when it grew by 0.5 percent. Of this, the riel component rose by 2.1 percent, to 1,311.3 billion riels, while the value of foreign currency deposits increased by 1.2 percent, to 3,189.3 billion riels equivalent to $791.2 million.

**Liquidity of the Banking System**

(billion riels)




*Note: Latest data available are for March 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅត្រីមាទី១ ២០០៥ ការនាំចេញសំលៀកបំពាក់របស់កម្ពុជាមានទំហំ ៤៤៥លានដុល្លារ ស្មើនឹង ១៤,៥% តិចជាងត្រីមាសទី៤ ២០០៤ ប៉ុន្តែ ១៦% ច្រើនជាងត្រីមាសទី១ ២០០៤ ។ ពីត្រីមាសទី៤ ២០០៤ ដល់ត្រីមាសទី១ ២០០៥ ការនាំចេញ កៅស៊ូ និងត្រី ថយចុះ ៣៩% ដល់ ៧,៣លានដុល្លារ និង ៦៦% ដល់ ១,៥លានដុល្លាររៀងគ្នា ចំណែកឯការនាំចេញអង្ករកើនច្រើនមួយទ្វេជាពីរ ដល់ ០,៨លានដុល្លារ ។

Cambodia's garment exports amounted to $445 million in the first quarter of 2005, 14.5 percent less than in fourth quarter 2004, but 16 percent more than in first quarter 2004. The trend of total exports mirrored the trend of garment exports. From the fourth quarter 2004 to first quarter 2005, exports of rubber and fish declined by 39 percent to $7.3 million and by 66 percent to $1.5 million, respectively, while exports of rice rose more than doubled to $0.8 million.

## Cambodia's Main Exports

(US$ million)




*Note: Latest data available are for March 2005.*
Source: Customs and Excise Department

នៅត្រីមាសទី១ ២០០៥ កម្ពុជានាំចូលបារី ៦៣,៥ពាន់លានរៀល, ស៊ីម៉ង់ត៍ ៤២,១ពាន់លានរៀល, និងដែក ២០,១ពាន់លានរៀល ។ ធៀបនឹងត្រីមាសមុន ការនាំចូលបារី ថយចុះ ៣២% រីឯការនាំចូល ស៊ីម៉ង់ត៍ និងដែក កើនឡើង ៩% និង ៦% រៀងគ្នា ។

In the first quarter of 2005, Cambodia imported 63.5 billion riels of cigarettes, 42.1 billion riels of cement and 20.1 billion riels of steel. Compared to the preceding quarter, imports of cigarettes declined by 32 percent, while imports of cement and steel increased by 9 percent and 6 percent.

## Imports of Cigarette and Construction Materials

(billion riels)




*Note: Latest data available are for March 2005.*
*(Excluding public sector imports)*
Source: Customs and Excise Department

ការនាំចូលផលិតផលប្រេងកាត (សាំង និងម៉ាស៊ូត) មានតំលៃ ១២២,៦ ពាន់លានរៀលនៅត្រីមាសទី១ ២០០៥ គឺបានថយចុះ ២,៤%ធៀបនឹងត្រីមាសមុន ។ ក្នុងនេះ ការនាំចូលម៉ាស៊ូតមាន ៨១,៥ពាន់លានរៀល (ថយចុះ ១៣,៥%) ឯការនាំចូលសាំងមាន ៤១,១ពាន់លានរៀល (ស្ទុះឡើង ៣១%) ។ បើធៀបនឹងត្រីមាសទី១ ឆ្នាំមុន ម៉ាស៊ូតនាំចូលថយចុះ ៣២,៤% ប៉ុន្តែសាំងនាំចូលកើនឡើង ៤៨% ។

Imports of petroleum products (gasoline and diesel oil) were worth 122.6 billion riels in first quarter 2005, a 2.4 percent decrease compared to the preceding quarter. Diesel imports accounted for 81.5 billion riels—a 13.5 percent decrease, while gasoline imports were 41.1 billion riels, a jump of 31 percent. Compared to the first quarter last year, imported diesel declined by 32.4 percent, but imported gasoline rose by 48 percent.

## Imports of Petroleum Products

(billion riels)




*Note: Latest data available are for March 2005.*
*(Excluding public sector imports)*
Source: Customs and Excise Department

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

ថវិកាសុរប ៣៩,៣លានដុល្លារ ត្រូវបានប្រមូលសំរាប់ទ្រទ្រង់កម្មវិធីសិលា នៅឆ្នាំ២០០៥ ធៀបនឹង ៤១,៤លានដុល្លារ នៅឆ្នាំ២០០៤ ។ ក្នុងនេះ រដ្ឋាភិបាលបន្តផ្តល់ច្រើនជាងគេគឺ ១៥លានដុល្លារ (១៣លាន នៅ ២០០៤) បន្ទាប់មកគឺ ភាពជាដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន ១២,២លាន និង IFAD ៦ លាន ហើយ ៦,១លានទៀតផ្តល់ដោយស្ថាប័ន និងប្រទេសជាច្រើន ។

A total of $39.3 million was mobilised to support Seila programmes in 2005, compared to $41.4 million in 2004. The government continued to provide the largest share—$15 million in 2005 ($13 million in 2004), followed by Partnership for Local Governance (PLG) and IFAD, which provided $12.2 million and $6 million, respectively, in 2005 ($11.7 million and $6.7 million in 2004). The remaining $6.1 million was supplied by UNICEF, Denmark, Germany, The WB, Australia, CONCERN, UNDP/DSP, Canada and GRET.

**Total Resources for Seila in 2005, by Major Donors**
(US$ million)




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ធនធានសំរាប់សិលា ក្នុងឆ្នាំ២០០៥ បានបែងចែកសំរាប់វិនិយោគ ការទ្រទ្រង់កម្មវិធី និងសហប្រតិបត្តិការបច្ចេកទេស ។ វិនិយោគប៉ាន់ស្មាន (កម្មវិធីឃុំ ខេត្ត/ក្រុង ជាតិ និងសេវារបស់ក្រសួងមាន ២៨,៧លានដុល្លារ (៧៣% នៃថវិកាសរុប) ធៀបនឹង ២៩,២លានដុល្លារនៅឆ្នាំ២០០៤ ។ ថវិកាគ្រោងសំរាប់ការទ្រទ្រង់កម្មវិធីគឺ ៥,២លានដុល្លារ (៦,១លាននៅឆ្នាំមុន) និងកិច្ចសហប្រតិបត្តិការបច្ចេកទេស ៥,៥លានដុល្លារ(៦,១លាននៅឆ្នាំមុន) ។

Resources for Seila in 2005 are allocated to investment, programme support and technical cooperation. Estimated investment, in communes and sangkats, provinces and municipalities, national programmes and ministry services, are $28.7 million (73 percent of the total budget) in 2005, compared to $29.2 million in 2004. Funding for programme support is projected at $5.2 million, compared to $6.1 million last year. Funds for technical cooperation are $5.5 million, down from $6.1 million.

**Seila Budget for 2005 by Main Categories**
(US$ million)




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

នៅឆ្នាំ២០០៥ ថវិកាសិលា សំរាប់វិនិយោគតាមខេត្ត មាន ៩,៣លានដុល្លារ ធៀបនឹង ១១,១លាននៅឆ្នាំមុន ។ ថវិកាសរុប ៤,៧លានដុល្លារបានបែងចែកទៅឱ្យមូលនិធិវិនិយោគខេត្ត ដែលជួយទ្រទ្រង់ដោយ PLG, Unicef, ដាណឺម៉ាក, កាណាដា, និង GRET, ឯថវិកា ៤,៦លានដុល្លារទៀត ផ្តល់ដោយកម្មវិធីនានាក្នុងវិស័យវិសហមជ្ឈការ ដែលទ្រទ្រង់ដោយ IFAD, រដ្ឋាភិបាលកម្ពុជា អាឡឺម៉ង់ អូស្ត្រាលី និងដាណឺម៉ាក ។

In 2005, the Seila budget for provincial investment amounts to $9.3 million, compared to $11.1 million in the previous year. A total of $4.7 million is allocated to the Provincial Investment Fund, which is supported by PLG, UNICEF, Denmark, Canada and GRET. The remaining $4.6 million represents Deconcentrated Sector Programmes, supported by IFAD, the Cambodian government, Germany, Australia and Denmark.

**Seila 2005 Budget for Provincial Investment**
(US$ million)




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ទិន្នន័យក្នុងច្រើនឆ្នាំកន្លងមកបង្ហាញថា ថវិកាចរន្តតែងមានអតិរេកនៅដើមឆ្នាំ ពីព្រោះចំណាយថវិកាចរន្តមានកំរិតទាបបំផុតនៅពេលនោះ ។ នៅខែមករា ២០០៥ អតិរេកថវិកាចរន្តមាន ១៦៩,៣ពាន់លានរៀល ធៀបនឹង ១៩៧,៥ពាន់លានរៀលនៅខែដូចគ្នាឆ្នាំ២០០៤ ។

Data over a number of years indicate that the current budget exhibits a surplus in the beginning of the year, mainly because current budget expenditure is lowest at that time. In January 2005, the current budget surplus was 169.3 billion riels, compared to 197.5 billion riels in the same month of 2004.

**Current Budget Operations**
(billion riels)




*Note: Provisional for January–December 2004 and January 2005.*
Source: Ministry of Economy and Finance

នៅខែមករា ២០០៥ ចំនូលថវិការចរន្ត មាន ១៧៨,៦ពាន់លានរៀល រឺ ១០,៥% តិចជាងខែដូចគ្នាឆ្នាំ២០០៤ ។ ចំនូលពន្ធថយចុះ ១៤% មកត្រឹម ១៤២,៨ពាន់លានរៀល ដែលក្នុងនេះ ពន្ធក្នុងស្រុកមាន ១០០,៩ពាន់លានរៀល (ថយចុះ ១,៨%) រីឯពន្ធគយមាន ៤១,៩ពាន់លានរៀល (ថយចុះ ៣៤%) ។ ចំនូលមិនមែនពន្ធកើន ៦,៣% ដល់ ៣៥,៨ពាន់លានរៀល ។ កំនើនក្នុងចំណូលទេសចរណ៏ (៣៧%) និងក្នុងប្រាក់កំរៃទិដ្ឋាការ (៥៨%) ជាខ្ចង់នាំមុខគេក្នុងកំណើនចំណូលមិនមែនពន្ធ ។

In January 2005, current budget revenue was 178.6 billion riels, 10.5 percent lower than in the same month of 2004. Tax revenue dropped by 14 percent to 142.8 billion riels, of which domestic tax accounted for 100.9 billion riels (a 1.8 percent decrease) and customs duties 41.9 billion riels (a 34 percent drop). Non-tax revenue increased by 6.3 percent to 35.8 billion riels. The increase in tourism income (37 percent) and visa fees (58 percent) led the increase in non-tax revenues.

**Current Budget Revenue**
(billion riels)




*Note: Provisional for January–December 2004 and January 2005.*
Source: Ministry of Economy and Finance

ចំនាយថវិកាចរន្តកើនដល់ ៩,៣ពាន់លានរៀលនៅខែមករា ២០០៥ ពីកំរិត ២ពាន់លានរៀលនៅខែមករា ២០០៤ ។ ចំណាយលើរដ្ឋបាលសង្គមកិច្ច រដ្ឋបាលទូទៅ និងចំណាយផ្សេងទៀត កើនដល់ ៦,៤ពាន់លានរៀល, ២,២ពាន់លានរៀល និង ០,៧ពាន់លានរៀលរៀងគ្នា ។ នៅខែមករា ២០០៥ គ្មានចំនាយខាងរដ្ឋបាលសេដ្ឋកិច្ច រឺខាងការពារជាតិ និងសន្តិសុខទេ ។

Current budget expenditure rose to 9.3 billion riels in January 2005, from about 2 billion riels in January 2004. Expenditures on social and general administration and other expenditure increased to 6.4 billion riels, 2.2 billion riels, and 0.7 billion riels, respectively. There were no expenditures on economic administration or defence and security in January 2005.

**Current Budget Expenditure**
(billion riels)




*Note: Provisional for January–December 2004and January 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

ផសស US ពិត កើន ៣,៥% ក្នុងរយៈមួយឆ្នាំដល់ចុងត្រីមាសទី១ ២00៥ គឺថយកំនើនពី ៣,៨% នៅត្រីមាសទី៤ ២00៤ ដោយវាឆ្លុះបញ្ចាំងពីការថយចុះក្នុងចំណាយទិញបរិក្ខារសូហ្វវែរ ចំនាយប្រើប្រាស់ និងការនាំចូល ។ ផសស ពិត នៅតំបន់អឺរ៉ូ នៅត្រីមាសទី១ ២00៥ មានកំរិត ១,៤% ខ្ពស់ជាងនៅត្រីមាសដូចគ្នាឆ្នាំមុន ។

US real GDP grew 3.5 percent in the year to first quarter 2005, a deceleration from 3.8 percent in fourth quarter 2004. The deceleration reflected declines in equipment and software, personal consumption expenditure and imports. Real GDP of the euro-zone in first quarter 2005 was 1.4 percent higher than in the same quarter of last year, and 0.5 percent higher than fourth quarter 2004. Japanese GDP grew 1.3 percent in real terms in the year to first quarter 2005. The expansion in Japan was driven by strong consumer spending and capital investment.

**GDP Growth Rate by Quarters**

(Percent change over a year earlier)




Sources: BEA, Eurostat and Bank of Japan

នៅត្រីមាសទី១ ២00៥ នៅចិន ផសស មានកំរិត ៩,៥% ខ្ពស់ជាងកាលពី ១ឆ្នាំមុន ដែលជំរុញដោយកំនើនលឿនក្នុងផលិតកម្មឧស្សាហកម្ម វិនិយោគ និងការនាំចេញ, នៅកូរ៉េខាងត្បូង ផផស កើន ២,៧% និងនៅហុងកុង កើន ៦,0% ។

China’s GDP in first quarter 2005 was 9.5 percent higher than a year earlier, driven by rapid growth in industrial production, investment and exports. The real GDP of South Korea in the first quarter 2005 grew at an annual rate of 2.7 percent compared with 3.3 percent growth in the fourth quarter 2004. The weak growth was attributable to static growth in exports and private consumption and a decline in construction investment. The real GDP of Hong Kong grew 6.0 percent in the first quarter 2005, compared with 7.2 percent growth in the fourth quarter 2004.

**GDP Growth Rate by Quarter**

(Percent change over a year earlier)




Sources: *Economist*, countries’ national statistics offices

ផសស ពិត នៅម៉ាឡេស៊ី ក្នុងរយៈមួយឆ្នាំដល់ចុងត្រីមាសទី១ ២00៥ កើន ៥,៧% (៥,៦% សំរាប់ត្រីមាសទី៤ ២00៤) ដែលជំរុញដោយគ្រប់វិស័យចំបងៗ លើកលែងតែខាងសាងសង់ចេញ ។ ក្នុងរយៈពេលដដែល ផសស ពិត នៅសិង្ហបុរី និងថៃ កើន ២,៥% និង ៣,៤% (ធៀបនឹង ៦,៥% និង ៥% សំរាប់ត្រីមាសទី៤ ២00៤) ។ នៅថៃ គេរំពឹងថា ផលប៉ះពាល់នៃគ្រោះស៊ូណាមី ការរាំងស្ងួត និងថ្លៃប្រេងខ្ពស់ នឹងធ្វើឱ្យធ្លាក់ចុះកំណើន ។

The real GDP of Malaysia in the year to first quarter 2005 grew 5.7 percent compared to 5.6 percent to fourth quarter 2004. The broad-based growth was driven by all major sectors of the economy except construction. Real GDP of Singapore and Thailand in the year to first quarter 2005 increased 2.5 percent and 3.4 percent respectively, a deceleration from 6.5 and 5 percent in the year to fourth quarter 2004. In Thailand, the impact of the tsunami, drought and high oil price is expected to cause growth to fall.

**GDP Growth Rate by Quarter**

(Percent change over a year earlier)




Sources: *Economist*, countries’ national statistics offices

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅជប៉ុនថយចុះ ០,២% ក្នុងរយៈពេល ១២ខែដល់ចុងខែមីនា ។ ការបន្តមានបរិត្តផរណាឆ្លុះបញ្ចាំងជាសំខាន់ពីការចុះថ្លៃកុំព្យូទ័រ អង្ករ និងទូរគមនាគមន៍ ។ ធនាគារកណ្តាលជប៉ុនត្រូវបានស្នើឱ្យបន្តគោលនយោបាយរក្សាអត្រាការប្រាក់នៅស្មើសូន្យ ព្រមទាំងបញ្ចូលសាច់ប្រាក់ទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ។ ក្នុងពេលនេះដែរ អតិផរណាមានអត្រាប្រចាំឆ្នាំ ២,១% នៅតំបន់អឺរ៉ូ និង ៣,១% នៅ US ។

Japan's consumer prices fell by 0.2 percent in the 12 months to March. The persistence of deflation largely reflected the drop in prices of personal computers, rice and telecommunications. The Bank of Japan was called on to maintain its policy of holding interest rates at zero while pumping cash into the financial system while moderate deflation lingers. During the same period, the inflation rate was unchanged at 2.1 percent per annum in the EU and rose slightly to 3.1 percent in the US.

## Inflation in the US, Europe and Japan

(Percent price change over previous year)




*Note: The latest data available are for Mach. 2005.*
Sources: IMF and *Economist* (14–20 May 2005)

អតិផរណាថ្លៃទំនិញប្រើប្រាស់នៅចិនចុះដល់ ២,៧% ក្នុងរយៈពេល ១ឆ្នាំដល់ខែមីនា ពីកំរិត ៣,៩% សំរាប់ខែកុម្ភៈ គឺបានកាត់បន្ថយការបារម្ភពីអតិផរណា និងការជួញលើប្រាក់យន់ ។ ក្នុងពេលដដែល កំនើនថ្លៃទំនិញប្រើប្រាស់នៅកូរ៉េខាងត្បូងធ្លាក់ចុះមកត្រឹម ៣,១% ដោយសារសាំង និងសេវាសាធា រណៈផ្សេងៗបានចុះថ្លៃ ឯនៅហុងកុង វានៅនឹងត្រឹម ០,៨% ។

China’s consumer inflation slowed to 2.7 percent in the year to March, from 3.9 percent in February, easing fears about inflation amid rampant speculation on the yuan. Meanwhile, South Korean consumer prices decelerated to 3.1 percent growth in the year to March as costs for gas and other public services dropped. During the same period, annual consumer price increases remained at 0.8 percent in Hong Kong.

## Inflation in China, Hong Kong and South Korea

(Percent price change over previous year)




*Note: The latest data available are for Mar. 2005*
Sources: IMF and the *Economist* (14–20 May 2005)

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅថៃ មានកំណើនឆ្នាំលើឆ្នាំយ៉ាងខ្លាំងដល់ ៣,២% នៅខែមីនា ធៀបនឹង ២,៥% នៅខែកុម្ភៈ ។ តាមសារពតិមាន The Nation នេះជាអត្រាអតិផរណាខ្ពស់បំផុតក្នុងរយៈ៧ខែ ដែលបណ្តាលជាសំខាន់ពីថាមពលថ្លៃខ្ពស់ ។ ក្នុងរយៈពេលដដែល អតិផរណាថ្លៃទំនិញប្រើប្រាស់ស្ទុះដល់ ០,៤% នៅសិង្ហបុរី និង ២,៦% នៅម៉ាឡេស៊ី ។

Thailand's consumer price index in March 2005 rose sharply to 3.2 percent year on year, up from 2.5 percent in the year to February. According to *The Nation*, this was the highest inflation rate in seven months and was mainly due to higher energy costs. During the same period, consumer inflation accelerated to 0.4 percent in Singapore and rose to 2.6 percent in Malaysia in the 12 months to March.

## Inflation in Selected ASEAN Countries

(Percent change over previous year)




*Note: The latest data available are for March 2005.*
Sources: IMF and the *Economist* (14–20 April 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែឧសភា ប្រាក់អឺរ៉ូបន្តចុះថ្លៃទល់នឹងដុល្លារ ដោយប្តូរបាន ០,៧៨៦អឺរ៉ូ/ដុល្លារ ។ ការធ្លាក់ថ្លៃនេះបណ្តាលពីកំនើនគំលាតអត្រាការប្រាក់រវាង US និងតំបន់អឺរ៉ូ និងការប្រមើលឃើញការចុះខ្សោយកំណើនក្នុងតំបន់អឺរ៉ូ ។ ក្នុងរយៈពេលដដែល ប្រាក់យ៉េនជប៉ុនឡើងថ្លៃទល់នឹងដុល្លារ ដោយប្តូរបាន ១០៦,៤៦យ៉េន/ដុល្លារ ហើយការឡើងថ្លៃនេះជាប់ទាក់ទិននឹងការវាយស្មានថា កំណើនសេដ្ឋកិច្ចនឹងស្ទុះឡើង ហើយបរិត្តផរណាគឺនៅតែមាន ។

In May, the euro continued to lose value against the dollar, trading at 0.786 to the dollar. The euro depreciation was attributable to the increase of the interest rate differential between the United States and the euro area and to the weaker growth prospects for the latter. During the same period, the Japanese yen appreciated against US dollar to 106.46. This upward pressure appears linked to speculation that economic growth is accelerating and deflation still persists.

### Euro and Japanese Yen Against US Dollar




*Note: Data are up to 27 May 2005.*
Sources: Federal Reserve Bank of New York

នៅខែឧសភា ដុល្លារហុងកុងឡើងថ្លៃបន្តិចដោយប្តូរបាន ៧,៧៩៣ដុល្លារហុងកុង/ដុល្លារUS ។ ក្នុងពេលដដែល ប្រាក់វ៉ុនកូរ៉េខាងត្បូងក៏ឡើងថ្លៃទល់នឹងដុល្លារដែរ ដោយប្តូរបាន ១០០១,៧៧វ៉ុន/ដុល្លារUS ដោយសារការចុះថ្លៃដុល្លារUS (ពីព្រោះទិន្នន័យអតិផរណា US បានកាត់បន្ថយលទ្ធភាពថាអត្រាការប្រាក់អាចកើនឡើងយ៉ាងច្រើនៗ) ។

In May, the Hong Kong dollar traded at 7.793, a slight appreciation against the US dollar. During the same period, the South Korean won also gained strength against the US dollar, trading at 1001.77, 1 percent stronger than a month earlier. The appreciation stemmed from the fall of the dollar as US inflation data dampened prospects for sharp rises in interest rate. Comments by a South Korean official to reduce support for the greenback also contributed to this appreciation.

### South Korean Won and Hong Kong Dollar Against US Dollar




*Note: Data are up to 27 May 2005.*
Sources: Federal Reserve Bank of New York

នៅខែឧសភា ដុល្លារសិង្ហបុរី ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ១,៦៤៩ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹង ១,៦៥៣ដុល្លារសិង្ហបុរី/ដុល្លារនៅខែមេសា ដោយសារការរំពឹងថា ជញ្ជីងពាណិជកម្មUS នឹងមានឱនភាពខ្ពស់បំផុត ។ ក្នុងពេលដដែល ប្រាក់បាតថៃបន្តធ្លាក់ថ្លៃទល់នឹងដុល្លារUS ដោយធនាគារកណ្តាលថៃបន្តរក្សាប្រាក់បាតឱ្យនៅថោក ដើម្បីជំរុញការនាំចេញដែលតំណាងឱ្យជិតពាក់កណ្តាលនៃសេដ្ឋកិច្ចថៃ ។

In May, the Singapore dollar advanced slightly against its US counterpart, trading at 1.649, from 1.653 in April. The main factor was the expectation of a record US trade deficit. Meanwhile, the Thai currency continued to erode against the US dollar as the Bank of Thailand maintained a policy favouring exports, which make up almost half of Thailand's economy by keeping the bath weak. The Thai baht traded at 39.73 this month compared to 39.51 in April.

### Thai Baht and Singaporean Dollar Against the US Dollar




*Note: Data are up to 27 May  2005.*
Sources: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែមេសា ថ្លៃអង្ករក្នុងផ្សារពិភពលោកមានស្ថិរភាពជាទូទៅ ។ ថ្លៃអង្ករនៅ US នៅខែមេសា នៅនឹងត្រឹម ៣០៩ដុល្លារ/តោន ។ នៅថៃ វាឡើងបន្តិចដល់ ២៩៩ដុល្លារ/តោន ធៀបនឹង ២៩៧ដុល្លារ/តោននៅខែមីនា ដោយសាររដ្ឋាភិបាលបានទិញអង្ករច្រើនៗ ធ្វើឱ្យថយចុះបរិមាណអង្ករសំរាប់នាំចេញ ហើយនិន្នាការថ្លៃក្នុងប៉ុន្មានខែខាងមុខ វាជាប់ទាក់ទិននឹងគោលនយោបាយថៃស្តីពីស្តុកអង្ករសាធារណៈ ។

In April, world rice prices remain globally stable. The international prices index (IPO) slightly decreased to 120.8 points from 121 in March. The rice prices in the US in April were stable selling at $309 per ton. In Thailand, prices rose slightly to $299 per ton from $297 per ton in March. The increase in Thailand was due to a supply restriction caused by massive government purchases, which resulted in reduction of exportable supply. The trend for coming months will depend on Thailand's policy on public stocks.

**International Prices Index and Export Rice Prices**
(US$/ton FOB)




Sources: Osiriz/InfoArroz and InterRice

នៅខែឧសភា សណ្តែកសៀងឡើងថ្លៃ ចំណែកឯពោតបានចុះថ្លៃ ។ សណ្តែកសៀងលក់ថ្លៃ ២៤៥,២៤ដុល្លារ/តោន រឺ ២% ខ្ពស់ជាងខែមេសា រីឯពោតលក់ថ្លៃ ៩៤,៤២ដុល្លារ/តោន រឺ ២% ទាបជាងខែមុន ។ ប្រេងឆាចុះថ្លៃដល់ ៤២៩ដុល្លារ/តោន រឺ ១% ទាបជាងខែមុន និង ២០% ទាបជាងខែមេសា ២០០៤ ។

In May, the price of soybeans rose while the price of maize fell. The price in of Soybeans in May was at $245.24 per ton, a 2 percent increase from April. Maize was sold at $94.42 per ton, about 2 percent lower than the month before. The price of palm oil in April declined about 1 percent from the previous month to $429 per ton, 20 percent lower than in April 2004.

**International Prices of Palm Oil, Soybeans and Maize**




Source: Food and Agriculture Organisation (FAO)

នៅខែឧសភា ប្រេងឆៅ និងសាំងបានចុះថ្លៃ ។ ថ្លៃលក់ដល់ដៃនៃប្រេងឆៅរបស់បណ្តាប្រទេស OPEC គឺ ៤៤,៩៩ដុល្លារ/ធុង រឺ ៧% ទាបជាងកាលពីខែមុន។ ថ្លៃលក់ដល់ដៃរបស់ OPEC គឺកំណត់ ១% ខ្ពស់ជាងថ្លៃលក់ដល់ដៃមធ្យមក្នុងប្រទេសទាំងអស់។ ថ្លៃសាំងធម្មតានៅ US Golf Coast នៅខែឧសភា ចុះដល់ ៣៧,១៨សេន/លីត្រ ធៀបនឹង ៤០,៦៥សេន/លីត្រ នៅខែមេសា ។

In May, the prices of crude oil and gasoline fell. The OPEC countries spot price of crude oil was $44.99 per barrel, a 7 percent decline from previous month. The spot price in OPEC countries is set 1 percent higher than the average spot price in all countries. Regular gasoline price in the US Gulf Coast in May dropped to 37.18 cents per litre, from 40.65 cents per litre in April.

**Prices of Crude Oil and Gasoline**




***Note: Data are up to 26 April** 2005*
Source: Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច
# Economic News

**SCC លើកផែនការធ្វើអាជីវកម្មចំរុះជាមួយកម្ពុជា:** SIAM Cement (SCC) ដែលជាក្រុមហ៊ុនផលិតស៊ីម៉ង់ត៍ធំបំផុតនៅថៃ បញ្ជាក់ថា ចង់ធ្វើអាជីវកម្មចំរុះរោងចក្រស៊ីម៉ង់ត៍តំលៃ ៣,២ពាន់លានបាតនៅកម្ពុជា ដែលរំពឹងថានឹងចាប់ផ្តើមធ្វើប្រតិបត្តិការនៅឆ្នាំ ២០០៨ ដោយមានសមត្ថភាពផលិត ៨៥០.០០០តោន/ឆ្នាំ ។ (*Business Day 26 May 2005*) ។

**ADB ផ្តល់កំចី ៤លានដុល្លារឱ្យកម្ពុជា:** ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានយល់ព្រមផ្តល់កំចី ៤លានដុល្លារឱ្យកម្ពុជា ដើម្បីពង្រីកព្រលានយន្តហោះនៅរតនគិរីសំរាប់ទទួលជើងហោះហើរអន្តរជាតិ យោងតាម Cambodia Daily ។ ព្រលានយន្តហោះថ្មី ស្ថិតក្នុងទីប្រជុំជន បានលុងនឹងរំពឹងថាបានហើយស្រេចបាច់នៅឆ្នាំ២០០៧ ។ នៅពេលមានដំណើរការព្រលាននេះ អាចឱ្យអ្នកទេសចរចូលមកតាមជើងហោះហើរផ្ទាល់ពីចិន និងវៀតណាម និងមកពីខេត្តសៀមរាបផង ។ ( ស្រង់ពី *Vietnam News Agency 19 May 2005*) ។

**ក្រុមហ៊ុនទូរគមនាគមន៍វៀតណាមចង់ធ្វើអាជីវកម្មជាមួយកម្ពុជា:** ក្រុមហ៊ុនវៀតណាមចំនួន ១០ ដែលមានឯកទេសខាងសេវា និងបរិក្ខារទូរគមនាគមន៍ បានចូលរួមក្នុងពិពណ៌បច្ចេកវិទ្យាពត៌មានអន្តរជាតិ នៅកម្ពុជា ដោយខិតខំស្វែងរកឱកាសធ្វើអាជីវកម្ម ដោយមានជាអាទិ៍ក្រុមហ៊ុនប្រៃសនីយ៍និងទូរគមនាគមន៍វៀតណាម (VNPT), ក្រុមហ៊ុនផ្តល់ហិរញ្ញប្បទាន និងជំរុញបច្ចេកវិទ្យា (FPT), ក្រុមហ៊ុនខ្សែកាប Vinadesung, និងរោងចក្របរិក្ខារប្រៃសនីយ៍ ។ វៀតណាមមើលឃើញកម្ពុជាជាទីផ្សារមានសក្តានុពលច្រើនសំរាប់បច្ចេកវិទ្យាព័ត៌មាន ។ មកទល់សព្វថ្ងៃ វិស័យប្រៃសនីយ៍ និងទូរគមនាគមន៍វៀតណាម បាននាំចេញគ្រឿងបរិក្ខារប្រហែល ២លានដុល្លារមកកម្ពុជា ( ស្រង់ពី *Vietnam News Agency 25 May 2005*) ។

**អាស៊ាន និង EU ចង់ធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី:** អាស៊ាន និង EU បានព្រមព្រៀងគ្នានៅថ្ងៃពុធ ២៥ ឧសភា ថានឹងធ្វើការសិក្សារួមគ្នាមួយពីភាពអាចធ្វើបាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងក្រុមប្រទេសទាំងពីរ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទៅអនាគត ។ ក្រុមការងារមួយដែលមានតំណាងមកពី EU និងអាស៊ាន នឹងធ្វើរបាយការណ៍ជាក់លាក់មួយនៅចុងឆ្នាំនេះ ។ ការផ្តួចផ្តើមគំនិតធ្វើពាណិជ្ជកម្មអន្តរតំបន់អាស៊ាន-EU (TREATI) ត្រូវបានធ្វើឡើងដោយ EU នៅឆ្នាំ២០០៣ ដើម្បីពង្រីកចំណងទាក់ទងរវាងតំបន់ទាំងពីរ នឹងក្លាយជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការទៅអនាគត ។ ( ស្រង់ពី *China View 30 May 2005*) ។

**SCC plans Cambodian joint venture:** SIAM Cement (SCC), Thailand's largest cement maker, said it wants to set up a 3.2 billion baht venture in Cambodia, where demand for cement remains strong. The plant is expected to begin operations by 2008 with an annual production capacity of 850,000 tonnes, the statement said. *(Cited from Business Day 26 May, 2005)*

**ADB provides $4 million loan to Cambodia:** The Asian Development Bank (ADB) has agreed to provide a $4 million loan to Cambodia to expand the Ratanakkiri airport to receive international fights, according to the Cambodia Daily. The new airport, located in Banlung town in Ratanakkiri province, is expected to be finished in 2007. Once operational, it will allow tourists to fly directly from China and Viet Nam, as well as from Siem Reap province. *(Cited from Vietnam News Agency 19 May 2005)*

**Vietnamese telecom firms seek deals with Cambodia:** Ten Vietnamese companies specialising in telecommunication services and equipment are participating in an international IT exhibition in Cambodia in an effort to explore business opportunities in the potential market. Among them are state giant Vietnam Post and Telecommunications Corporation (VNPT), Corporation for Financing and Promoting Technology (FPT), Vinadaesung Cable Company and Postal Equipment Factory. Vietnam considers Cambodia an information technology market of great potential. To date, the Vietnamese post and telecommunications sector has exported about $2 million worth of equipment to Cambodia. *(Cited from Vietnam News Agency 25 May 2005)*

**ASEAN, EU eye free trade agreement:** ASEAN and the European Union (EU) agreed Wednesday [25 May] to conduct a joint feasibility study into a potential free trade agreement between the two blocs and their future economic cooperation. A working group with representatives from the EU and ASEAN would make specific reports by the end of this year. The Trans-Regional EU-ASEAN Trade Initiative (TREATI), initiated by the EU in 2003 to beef up trade and investment ties between the regions, will serve as a pillar of their cooperation in the future. *(Cited from China View 30 May 2005)*


**To Subscribe Please Contact:**

| | |
|---|---|
| *Office Address:* | #56, Street 315, Tuol Kork, Phnom Penh, Cambodia |
| *Postal Address:* | CDRI, PO Box 622 Phnom Penh, Cambodia |
| *Tel:* | (855-23) **881-384/881-701/881-916/883-603** |
| *Tel/fax:* | (855-23) **880-734** |
| *E-mail:* | pubs@cdri.forum.org.kh |
| *Website:* | http://www.cdri.org.kh |
| *Office hours:* noon | 7:30 am - 12:00 |